ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,
Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN Saray
ជាប្រធានគណៈកម្មាធិការនាយក និងជាប្រធានសមាគម ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
ជាអនុប្រធានគណៈកម្មាធិការនាយក និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គហិរញ្ញិក និងជានាយក CCPCR

លោក **យៀង វណ្ណា**
Mr. YEANG Vanna
ប្រធាន KKKHRA

លោក **ជីវ យូម៉េង**
Mr. CHIV You Meng
ប្រធាន KYA

លោកស្រី **ពឹង យក់ហៀប**
Ms. PEUNG Yok Hiep
នាយិកា LAC

លោក **យង់ គិមអេង**
Mr. YONG Kim Eng
ប្រធាន PDP Center

លោក **ទូច ទុម្ព**
Mr. TOUCH Tum
នាយក VIGILANCE

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

កញ្ញា **សយ សារា វឌ្ឍនី**
Ms. SAY Sara Vathany
នាយិកា CWCC

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith
**ឥស្សរជន**

លោក **សឺន សែត**
Mr. SEN Set
**ឥស្សរជន**

*អត្ថបទលេខ ៨២*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីអំពី
# ពិធីប្រគល់រង្វាន់ អ្នកឃ្លាំមើលមូលដ្ឋានឆ្នើម

*ភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១០*

គណៈកម្មាធិការ(ខុមហ្វ្រែល) មានកត្តិយសជំរាបជូន សាធារណៈជនអោយបានជ្រាបថា ខុមហ្វ្រែល បានប្រារព្ធពិធីប្រគល់រង្វាន់ សំរាប់អ្នកឃ្លាំមើលមូលដ្ឋានចំនួន ០៤រូប ។ អ្នកឃ្លាំមើលទាំង៤ រូបនេះគឺជាបណ្តាញរបស់ខុមហ្វ្រែលនៅថ្នាក់មូលដ្ឋានដែលពួកគេបានចូលរួមស្ម័គ្រចិត្ត ក្នុងការងារសង្កេត ឃ្លាំមើលក្រុមប្រឹក្សាមូលដ្ឋាន។ ពួកគេបានចូលរួមបង្កើតការទំនាក់ទំនង ឬវេទិកាពិភាក្សារវាងប្រជាពលរដ្ឋជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។ ពួកគេត្រូវបានវាយតម្លៃ អោយជាប់ចំណាត់ថ្នាក់ឆ្នើម លើការបំពេញកិច្ចការមូលដ្ឋាននៅក្នុងឃុំ សង្កាត់របស់ពួកគេផ្ទាល់សំរាប់ឆ្នាំ ២០០៨-២០០៩។ ក្រៅពីកិច្ចការខាងលើពួកគាត់ក៏បាន ផ្តួចផ្តើមគំនិត ជួយធ្វើអន្តរាគមន៏ ធ្វើរបាយការណ៏ និងជាអ្នកទំនាក់ទំនងពាំនាំព័តិមានពីប្រជាពលរដ្ឋ ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ហើយពីក្រុមប្រឹក្សាឃុំ សង្កាត់ទៅប្រជាពលរដ្ឋវិញ និងកិច្ចការផ្សេងទៀតដែលបំរើឱ្យផលប្រយោជន៏ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន។

នេះជាលើកទីមួយហើយដែល ខុមហ្វ្រែលបានរៀបចំការវាយតម្លៃដើម្បីផ្តល់រង្វាន់សំរាប់អ្នកឃ្លាំមើលមូលដ្ឋាននេះឡើង។ ដំណើរការនៃកម្មវិធីនេះមានរយៈពេលមួយខែ គឺចាប់ផ្តើមពីដើមខែធ្នូ ហើយបញ្ចប់នៅចុងខែធ្នូ ឆ្នាំ ២០០៩។ ការវាយតម្លៃបានរកឃើញមានអ្នកឃ្លាំមើលចំនួន ០៤រូបជាប់ចំណាត់ថ្នាក់ពីលេខ១ ដល់លេខ៣និងម្នាក់ទៀតជាប់រង្វាន់លួងចិត្ត ត្រូវបានជ្រើសរើស ចេញពីបេក្ខជនចំនួន ៤២រូប មកពី ០១ រាជធានី ២០ខេត្ត ដែលបានដាក់ពាក្យសុំធ្វើការប្រកួតប្រជែង។ ក្រុមការងារវាយតម្លៃរបស់ខុមហ្វ្រែលបានចុះពិនិត្យដល់មូលដ្ឋានដើម្បីសំភាសន៏ផ្ទាល់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ប្រជាពលរដ្ឋនៅឃុំ សង្កាត់របស់ពួកគេ

ឆ្លងតាមលទ្ធផលរបស់គណៈកម្មការវាយតម្លៃ លើការបំពេញកិច្ចការមូលដ្ឋាន យើងទទួលបាន៖



-ចំណាត់ថ្នាក់លេខ១ បានទៅលើ **លោក ភន សាវឌ្ឍ** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំបន្ទាយនាង ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃអន្តរាគមន៏ លើបញ្ហាកើតមាននៅក្នុង ឃុំ សង្កាត់ដើម្បីអោយក្រុមប្រឹក្សាឃុំ សង្កាត់ ជួយដោះស្រាយ។



-ចំណាត់ថ្នាក់លេខ**២** បានទៅលើ **លោកតាក លឹម** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង ដែលមានស្នាដៃលើការទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន ។




-ចំណាត់ថ្នាក់លេខ**៣** បានទៅលើ **លោក យ៉ាង ថន** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំបាតាង ស្រុកលំផាត់ ខេត្តរតនៈគិរី មានស្នាដៃលើការចូលរួម កសាងសាលាប្រជុំភូមិ និងជំរុញការដោះស្រាយបញ្ហាដីធ្លី ។

-រង្វាន់លួងចិត្ត បានទៅលើ **លោកស្រី មាស សុខេន** ជាអ្នកឃ្លាំមើលមូលដ្ឋានមកពី ឃុំតុងរ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចាម លោកស្រីបានចូលរួមលើកសំណើរប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីលើកបញ្ហានៅមូលដ្ឋាន ។

កម្មវិធីផ្តល់រង្វាន់នេះ បានប្រព្រឹត្តទៅថ្ងៃទី២៧ ខែមករា ឆ្នាំ ២០១០ វេលាម៉ោង២រសៀល នៅទីស្នាក់ការកណ្តាលខុមហ្វ្រែល ដែលមានការអញ្ជើញចូល រួមពីគណៈកម្មាធិការប្រតិបត្តិ គណៈកម្មាការវាយតម្លៃ និងលេខារាជធានី ខេត្តខុមហ្វ្រែលទាំង២៤។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាព័ត៌មានដល់សាធារណៈជនជ្រាប ។

សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង

-លោក គឹម ឈន អ្នកសំរបសំរួលកម្មវិធីជាន់ខ្ពស់ខុមហ្វ្រែល ០១២ ៩៤២ ០១៩

-លោក ប្លង ឃឿត មន្ត្រីផ្នែកបណ្តាញ និងវេទិកាសាធារណៈ ០១២ ៤៧១ ៣២៦